55/04

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងរដ្ឋប្បវេណី

លេខ:១៧៣/២៣.៥.២០១៣

សាលដីកា

លេខ:២៧ក្រ.VI(ធ)/១១.១០.២០១៣

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី១១-១០-២០១៣

ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

ក្រឡាបញ្ជីសវនាការ

លោក [redacted]

-ដើមចោទឈ្មោះ [redacted] ឈួន ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] ប្រុក(រ) ម្តាយឈ្មោះ [redacted] អួន(ស) ប្រពន្ធឈ្មោះ [redacted] ខេន ។(ប្តឹងឧទ្ធរណ៍)

មានមេធាវីតំណាងដោយអាណត្តិលោកស្រីមេធាវី [redacted]

-ចុងចម្លើយឈ្មោះ [redacted] សារ៉េត ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរនគរបាលស្រុកបុទុមសាគរ មានទីលំនៅភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង ឪពុកឈ្មោះ [redacted] ហ៊ាំ(ស) ម្តាយឈ្មោះ [redacted] ហោ(រ) ប្រពន្ធឈ្មោះ [redacted] សុខឿន ។

កម្មវត្ថុ: ប្តឹងទាមទារសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម: ដើមចោទ

-ទាមទារដីភូមិទំហំ ២០ម គុណ ១០០ម មានទីតាំងនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ។

-ទាមទារដីចំការទំហំ ២០ម គុណ ៣០០ម មានទីតាំងស្ថិតនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង។

-ទាមទារដីស្រែប្រាំងទំហំ ២១ម គុណ ២៧០ម មានទីតាំងនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ។

និងទាមទារដីចំការទំហំ ៨ម គុណ ៧០០ម មានទីតាំងនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង។

២៥១



Scanned with CamScanner

<u>**បណ្ដឹងតបរបស់ចុងចម្លើយៈទាមទារដីដូចខាងក្រោម**</u>

-ទី១ ដីប្រាំងមានទំហំ ១៩.៥០ម គុណ ៥០០ម មានព្រំប្រទល់ខាងកើតទល់ទឹក ខាងលិចទល់នឹងដី ឈ្មោះ [redacted] ហោ ខាងជើងទល់ដីឈ្មោះ [redacted] យ៉ាន់ ខាងត្បូងទល់ដីឈ្មោះ [redacted] សាឯម ។

-ទី២ ដីចំការ(ដីឡូត៍) មានទំហំ៨ម គុណ ៧០០ម មានព្រំប្រទល់ខាងកើតទល់នឹងផ្លូវរទេះ ខាងលិចទល់នឹងផ្លូវរទេះ ខាងជើងទល់នឹងដីឈ្មោ [redacted] សន ខាងត្បូងទល់នឹងដីឈ្មោះ [redacted] សាឯម ។

-ទី ៣ ដីភូមិនិងដីចំការមានទំហំ២០ម គុណ ៥០០ម មានព្រំប្រទល់ ខាងកើតទល់នឹងទន្លេ ខាងលិចទល់ដីប្រាំង ខាងជើងទល់ដីឈ្មោះ [redacted] ថាវី ខាងត្បូងទល់ដីឈ្មោ [redacted] ហួយ ។ ដីទាំងបីកន្លែងស្ថិតនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ។

<u>**អង្គហេតុ និងចំណុចវិវាទៈ**</u>

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៣-សីហា-២០១២ របស់ឈ្មោះ [redacted] ឈួន និងប្រពន្ធឈ្មោះ [redacted] ខេន ដើមចោទប្ដឹងថា ខ្លួននិងប្រពន្ធបានរស់នៅលើដីភូមិដីធ្វើចំការ និង ដីប្រាំង ដែលមានទីតាំងនិងទំហំដូចមាននៅក្នុងកម្មវត្ថុបណ្ដឹងតាំងពីឆ្នាំ១៩៨៤ ពុំដែលមានទំនាស់ និង ពុំមាននរណាមកអះអាងដីទាំងនេះជារបស់អ្នកណាទេ ចេះតែរស់នៅលើដីភូមិនិងធ្វើស្រែចំការតរៀងៗមក ។ ទើបតែនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ មានសេចក្ដីជូនដំណឹងរបស់លោកមេឃុំអង្គរអង្គស្ដីទីឈ្មោះ [redacted] ហួន បានជូនដំណឹងដល់ខ្លួននិងប្រពន្ធ ឱ្យរុះរើ ឬ សែងផ្ទះចេញពីដីរបស់ឈ្មោះ [redacted] សារ៉េត និងប្រពន្ធឈ្មោះ [redacted] សុឡឿន ចាប់ពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ ជាកំណត់ដើម្បីឱ្យម្ចាស់កម្មសិទ្ធិចូលមកគ្រប់គ្រងលើទ្រព្យសម្បត្តិ និង ចំពោះដើមឈើក៏ត្រូវគាស់ ឬ ត្រូវកាប់ចេញផងដែរ ធ្វើឱ្យរូបខ្លួននិងប្រពន្ធព្រមទាំងក្រុមគ្រួសារទាំងមូលភ្ញាក់ផ្អើល។

បានឃើញរបាយការណ៍រឿងរដ្ឋប្បវេណីលេខ១៧៣ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

**ការអះអាងរបស់គូភាគី**

-មេធាវីឈ្មោះ [redacted] ចន្ទលីដា តំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ឈួន ថ្លែងហេតុថាៈ កូនក្ដីខ្លួនមិនសុខចិត្តប្ដឹងឧទ្ធរណ៍ដើម្បីទាមទារដីចំនួន០៤កន្លែងដែលមានទំហំ២០ម គុណ ១០០ម, ២០មគុណ៣០០ម, ៦១ម គុណ ២៧០ម និង ៨ម គុណ ៧០០ម ស្ថិតនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង គឺកូនក្ដីខ្លួនបានកាន់កាប់និងរស់នៅតាំងពីឆ្នាំ១៩៨៤ មកជាមួយឪពុកម្ដាយ ហើយនៅឆ្នាំ២០០០ ឪពុកម្ដាយកូនក្ដីខ្លួនបានទៅនៅខេត្តកោះកុង ។ នៅឆ្នាំ១៩៨៨ ឈ្មោះ [redacted] សារ៉េត បានមកទាមទារដីនេះដោយសំអាងថាមានលិខិតផ្ទេរសិទ្ធិ តែតាមពិតកូនក្ដីខ្លួនបានរស់នៅលើដីនេះជាង៣០ឆ្នាំមកហើយ ដូច្នេះតាមច្បាប់ភូមិបាលឃើញថាដីនេះជាកម្មសិទ្ធិស្របច្បាប់របស់កូនក្ដីខ្លួន ប៉ុន្តែកូនក្ដីខ្លួនមិនបានធ្វើពាក្យសុំកាន់កាប់ដីទាំងនេះទេ តែមេភូមិនិងប្រធានប៉ុស្ដិ៍បានដឹងឮ ហេតុនេះក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] ឈួន សូមសំណូមពរសុំឱ្យទាត់ចោលសាលក្រមរបស់សាលាដំបូងខេត្តព្រៃវែង និង សម្រេចប្រគល់ដីទាំង០៤កន្លែងមកឱ្យកូនក្ដីខ្លួនកាន់កាប់រស់នៅដដែល ។



Scanned with CamScanner

-ដើមចោទឈ្មោះ[redacted] ឈួន ថ្លែងហេតុថាៈ ពេលធ្វើលិខិតផ្ទេរសិទ្ធិខ្លួនមិនព្រមផ្តិតមេដៃទេ ។ ទោះបីខ្លួនចាំដីឱ្យអ្នកដទៃពេលគេលក់ក៏ខ្លួនត្រូវបានមួយចំណែកដែរ ។ ខ្លួនពិតជាបានជួលដីនេះចំនួន០៥ឆ្នាំមែន ។ ប្រពន្ធខ្លួនមិនចេះអក្សរជាអ្នកធ្វើជាមួយមេឃុំ ឯខ្លួនមកធ្វើសំណង់នៅភ្នំពេញ ។ បើប្អូនយកដីនេះលក់ឱ្យអ្នកដទៃខ្លួនមិនព្រមចេញទេ សុខចិត្តស្លាប់នៅលើដីនេះ តែបើប្អូនលក់ឱ្យបងៗសុខចិត្តបង់ឱ្យប្អូនក្នុង០១ឆ្នាំ២០០០$(ពីរពាន់ដុល្លាអាមេរិក) ។

-ឈ្មោះ [redacted] សារ៉េត ចុងចម្លើយថ្លែងហេតុថាៈ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៤ បងប្អូនទាំងអស់គ្នារស់នៅជាមួយគ្នាជាមួយឪពុកម្តាយ ដល់ឆ្នាំ១៩៨៨ គាត់ក៏បានបែកចេញពីឪពុកម្តាយទៅរស់នៅកន្លែងផ្សេង ។ ក្រោយមកគាត់បានលក់ដីរបស់គាត់ហើយមកសុំរស់នៅជាមួយឪពុកម្តាយ ។ នៅឆ្នាំ១៩៨៨ ខ្លួននិងប្រពន្ធបានមកចាក់ដីនិងចាក់ជើងសសរចំនួន១៥ដើមនៅលើដីនេះដើម្បីធ្វើផ្ទះ តែដោយមានធុរៈក៏មិនបានធ្វើផ្ទះ ។ នៅឆ្នាំ២០០០ ឪពុកម្តាយបានទៅរស់នៅខេត្តកោះកុង តែគាត់តែងតែទៅមកមិនដែលខាន ហើយឈ្មោះ[redacted] ឈួន ក៏មករស់នៅលើផ្ទះនេះ ហើយផ្ទះនេះបងនៅកោះកុងជាអ្នកធ្វើឱ្យឪពុកម្តាយរស់នៅ ។ ដីភូមិនេះបង[redacted] ឈួន បានយកទៅបញ្ចាំគេ ខ្លួនក៏ទៅលោះយកមកទៀត ។ ដីភូមិនេះខ្លួនបានប្រាប់ឱ្យគាត់ចាកចេញរកដីផ្សេងរស់នៅ ខ្លួនត្រូវមករស់នៅវិញព្រោះខ្លួនចាស់ជិតចូលនិវត្តន៍ហើយ ។ ដីឪពុកម្តាយមានទំហំ២០ម ហើយឪពុកម្តាយចែកឱ្យប្អូន០២នាក់ម្នាក់ៗ១០ម ។ ពេលនោះប្អូនឈ្មោះ[redacted] ភស័ បានលក់ដី១០មឱ្យគាត់ ព្រោះគ្នាមានធុរៈត្រូវការលុយ តែគាត់មិនយកទេ ប្អូនក៏ទូរស័ព្ទមកខ្លួននៅកោះកុង ខ្លួនក៏សុខចិត្តយកដីនោះទៅ ហើយខ្លួនក៏ធ្វើលិខិតកិច្ចសន្យាផ្ទេរសិទ្ធិ ។ ចំពោះដីដែលគាត់ជួលខ្លួនរយៈពេល ០៥ឆ្នាំ សូមឱ្យ គាត់ទូទាត់លុយមកឱ្យខ្លួន និង សំណូមពរសុំឱ្យគាត់ប្រគល់ដីទាំងអស់មកឱ្យខ្លួនកាន់កាប់ដូចដែលសាលាដំបូងខេត្តព្រៃវែង បានសំរេច ។

**សំអាងហេតុ**

**យល់ឃើញថា**

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ឈ្មោះ[redacted] ឈួន ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២- ដើមចោទបានប្តឹងទាមទារដីចំនួនបីកន្លែងគឺដីទំហំ២០m × ១០០m, ដីទំហំ២១m × ២៧០m, និងដីទំហំ៨m × ៧០០m ស្ថិតនៅភូមិវាលរបងក្រោម ឃុំអង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង ពីចុងចម្លើយដោយសំអាងថា ដីនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ ១៩៨៤ រហូតមក ។

៣-តាមចម្លើយបំភ្លឺរបស់គូភាគី, តាមការបំភ្លឺរបស់សាក្សី និង តាមការបំភ្លឺរបស់អាជ្ញាធរមូលដ្ឋាន បានបញ្ជាក់ថា ដីទំនាស់នេះជាដីដែលគ្រប់គ្រងដោយឈ្មោះ [redacted]ស៊ាន ប្រពន្ធឈ្មោះ [redacted] អ៊ុន ដែលត្រូវជាឪពុកម្តាយដែលបានកាន់កាប់គ្រប់គ្រង តាំងតែពីឆ្នាំ១៩៧៩មក ហើយឈ្មោះ[redacted] ឡឿន និង [redacted] ភ័ស បានរស់នៅក្នុងបន្ទុករបស់ឈ្មោះ [redacted]ស៊ាន និង [redacted] អ៊ុន ជាឪពុកម្តាយរហូតមក ។ ដោយឡែកឈ្មោះ[redacted] ឈួន និង [redacted]ខេន គឺរស់នៅដោយឡែក ដោយរដ្ឋអំណាចបានបែងចែកដីឱ្យអ្នកទាំងពីរនេះដាច់ដោយឡែករួចហើយ ។ លុះដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឈ្មោះ[redacted] ស៊ាន និង [redacted] អ៊ុន បានផ្ទេរសិទ្ធិកាន់កាប់ដីនេះមកឲ្យឈ្មោះ[redacted] ភ័ស និង[redacted] ឡឿន



Scanned with CamScanner

កាន់កាប់គ្រប់គ្រងបន្ត ។ ហើយនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ឈ្មោះ [redacted] ភ័ស បានផ្ទេរសិទ្ធិកាន់កាប់ដីចំណែករបស់ខ្លួនមកឱ្យឈ្មោះ [redacted] ឡឿន កាន់កាប់គ្រប់គ្រងទៀត ។

៤-ដីទំនាស់នេះជាដីរបស់ឈ្មោះ [redacted] ស៊ាន និង [redacted] អ៊ុន ហើយឈ្មោះ [redacted] ស៊ាន និង [redacted] អ៊ុន បានផ្ទេរសិទ្ធិកាន់កាប់នេះឱ្យមកឈ្មោះ [redacted] ឡឿន និង [redacted] ភ័ស តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ហើយឈ្មោះ [redacted] ភ័ស ក៏បានផ្ទេរសិទ្ធិកាន់កាប់ដីចំណែករបស់ខ្លួន ឱ្យមកឈ្មោះ [redacted] ឡឿន តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយ ដូច្នេះចុងចម្លើយឈ្មោះ [redacted] ឡឿន និងប្តីឈ្មោះ [redacted] សារ៉េត មានសិទ្ធិក្នុងការកាន់កាប់គ្រប់គ្រងដីទំនាស់របស់ខ្លួន ។

៥-ដើមចោទបានអះអាងថាដីទំនាស់នេះជាដីរបស់ខ្លួន ប៉ុន្តែតាមកិច្ចសន្យាចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ បានបញ្ជាក់ថា ឈ្មោះ [redacted] ឈួន បានជួលដីទំនាស់ពីចុងចម្លើយដើម្បីបង្កបង្កើនផលក្នុងរយៈពេល៥ឆ្នាំតែប៉ុណ្ណោះ។ ហើយតាមកិច្ចសន្យា ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១ បានបញ្ជាក់ថា ចុងចម្លើយបានប្រគល់ដីទំហំក្បាលប្រវែង១០ម ឱ្យទៅដើមចោទរស់នៅ ដោយមានលក្ខខ័ណ្ឌថាឈប់បង្ករឿងទៀត ដែលបញ្ជាក់ឱ្យឃើញថាដើមចោទបានទទួលស្គាល់ថា ដីនេះជារបស់ចុងចម្លើយ ហើយខ្លួនគ្រាន់តែបានសុំជួល និង សុំគេរស់នៅតែប៉ុណ្ណោះ ។

៦-រឿងក្តីនេះសាលាដំបូងខេត្តព្រៃវែង បានធ្វើការអង្កេតនិងលើកយកភស្តុតាង មកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូច្នេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

៧-សាលក្រមរដ្ឋប្បវេណីលេខ:០៦(ក)រ.វ ចុះថ្ងៃទី២០.០២.២០១៣ របស់សាលាដំបូងខេត្តព្រៃវែង ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ គប្បីរក្សាទុកជាបានការដដែល ។

**សេចក្តីសម្រេចបញ្ចប់**

១-ច្រានពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦-០២-២០១៣ របស់ឈ្មោះ [redacted] ឈួន ចោល ។

២-រក្សាសាលក្រមរដ្ឋប្បវេណីលេខ:០៦(ក)រ.វ ចុះថ្ងៃទី២០.០២.២០១៣ របស់សាលាដំបូងខេត្តព្រៃវែងទុកជាបានការដដែល ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

៤-សាលដីកានេះប្រកាសជាសាធារណៈនាថ្ងៃទី១១.១០.២០១៣ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងអំឡុងពេល០១(មួយ)ខែ គិតចាប់ពីពេលដែលបានទទួលការបញ្ជូនសាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|

ហត្ថលេខា: [redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សា

[redacted]

២៨៤

284

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី...០៨...ខែ...11.....ឆ្នាំ២០13..
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner